

# វគ្គសិក្ខាសាលាឆ្នាំ ២០២៥
# កិច្ចគាំពារការសម្រេចចិត្តរបស់អ្នកពេញវ័យ

## វគ្គទី ១៖ កិច្ចគាំពារការសម្រេចចិត្តក្នុងផ្នែកអប់រំ

CPR Center for Public Representation

# ស្វាគមន៍

- អង្គការមជ្ឈមណ្ឌលធ្វើបទបង្ហាញជាសាធារណៈ
  - Mona Igram, មានអាជ្ញាប័ណ្ណផ្នែកច្បាប់នៅរដ្ឋ ម៉ាសាឈូសេត
  - Megan Rusciano, មានអាជ្ញាប័ណ្ណផ្នែកច្បាប់តែនៅរដ្ឋ ម៉ារីឡែន
  - Morgan Whitlatch, មានលិខិតអនុញ្ញាតផ្នែកច្បាប់នៅរដ្ឋ ម៉ាសាឈូសេត

# សូមបង្ហាញជូនវគ្គសិក្ខាសាលា ដែលមានបីផ្នែក ស្តីពីការគាំពារការសម្រេចចិត្ត ក្នុងផ្នែក៖



វគ្គ១៖
ការអប់
ថ្ងៃនេះ



វគ្គ២៖
ការថែទាំសុខភាព
២២ កុម្ភៈ



វគ្គ៣៖
ហិរញ្ញវត្ថុ
២៩ មីនា

# ប្រធានបទថ្ងៃនេះ



- **សាវតារ**
  - តើមានអ្វីកើតឡើង នៅវ័យ ១៨ ឆ្នាំ?
  - តើអ្វីជាអាណាព្យាបាលភាពអ្នកពេញវ័យ?
  - តើហេតុអ្វីចាំបាច់គិតគូរអំពីជម្រើសផ្សេងសិន?
  - តើការសម្រេចចិត្តដោយមានកិច្ចគាំពារគឺជាអ្វី?
- **ការគាំពារការសម្រេចចិត្តក្នុងផ្នែកអប់រំ**
  - ឧទាហរណ៍ជាក់ស្តែង
  - ឯកសារដែលអាចប្រើបាន
    - ទម្រង់ Massachusetts 2024 IEP Form
    - ទម្រង់ “FERPA” អនុញ្ញាតបញ្ចេញព័ត៌មាន
    - ការរួមគ្នាសម្រេចចិត្តផ្នែកអប់រំ
    - ការចាត់ឲ្យអ្នកដទៃសម្រេចចិត្តផ្នែកអប់រំ

# តើមានអ្វីកើតឡើង ពេលកូនពិការរបស់ខ្ញុំ ឈានចូលវ័យ ១៨ ឆ្នាំ?

- នៅរដ្ឋម៉ាសាឈូសេត កាលណានរណាម្នាក់ឈានចូលវ័យ ១៨ ឆ្នាំ គឺគាត់ក្លាយជានីតិជន (មនុស្សពេញវ័យ)។
- បើតាមច្បាប់ អ្នកពេញវ័យបែបនេះ ពួកគាត់អាចសម្រេចចិត្តអ្វីបានខ្លួនឯង មិនចំពោះថាពួកគាត់ពិការ ឬមិនពិការនោះឡើយ។
- បើនៅសាលារៀន គេហៅករណីថាជា "ការផ្ទេរសិទ្ធិ"



# ឯកសារផ្លូវច្បាប់សំខាន់ៗ សម្រាប់ការសម្រេចចិត្តផ្នែកអប់រំ នៅរដ្ឋម៉ាសាឈូសេត

- ការសម្រេចចិត្តដែលមានកិច្ចគាំពារ
- ការរួមគ្នាសម្រេចចិត្តផ្នែកអប់រំ
- ការចាត់ឲ្យអ្នកដទៃសម្រេចចិត្តផ្នែកអប់រំ
- អាណាព្យាបាលភាពបង្គាប់ដោយតុលាការ



# តើអាណាព្យាបាលភាពលើអ្នកពេញវ័យ ជាអ្វី?



- ខុសគ្នាពីអាណាព្យាបាលភាពលើកុមារ
- អាណាព្យាបាលភាព = តុលាការ
- ដំណើរការផ្លូវច្បាប់ ដែលតុលាការសម្រេចថាអ្នកពេញវ័យណាម្នាក់ "**បាត់បង់សមត្ថភាព**" និងចាត់តាំងនរណាម្នាក់ផ្សេងឲ្យ (ធ្វើជា"**អាណាព្យាបាល**") ដើម្បីសម្រេចចិត្តគ្រប់យ៉ាង ឬខ្លះជំនួយអ្នកនោះ។

# តើអ្វីជាប្រការ "មិន" ចំពោះអាណាព្យាបាលភាពលើអ្នកពេញវ័យ?



- អាណាព្យាបាលភាព មិនមែនជាជម្រើសតែមួយគត់សម្រាប់គិតគូរ
- អាណាព្យាបាលភាព មិនមែនគ្រាន់តែជាក្រដាសមួយសន្លឹក
- អាណាព្យាបាលភាព មិនមែនជាការធានាសុវត្ថិភាព
- អាណាព្យាបាលភាព មិនមែនគ្មានចំណុចអាក្រក់

# តើមានជម្រើសអ្វីផ្សេងខ្លះទៀត ក្នុងផ្នែកអប់រំ?

- ការសម្រេចចិត្តដែលមានកិច្ចគាំពារ
- ការរួមគ្នាសម្រេចចិត្តផ្នែកអប់រំ
- ការចាត់តាំងឲ្យអ្នកដទៃសម្រេចចិត្តផ្នែកអប់រំ



# តើការសម្រេចចិត្តដោយមានកិច្ចគាំពារ គឺជាអ្វី?



- មនុស្សសម្រេចចិត្តរឿងផ្ទាល់ខ្លួន ដោយមានជំនួយពីអ្នកដទៃ ដែលពួកគាត់ជ្រើសរើស និងទុកចិត្ត។
- អ្នកជួយនោះ ផ្តល់ជា**ការណែនាំ និងជំនួយ**។
- អាចជា**ផ្លូវការ(ជាលាយលក្ខណ៍អក្សរ)**ឬក្រៅ**ផ្លូវការ**។
  - "កិច្ចព្រមព្រៀងគាំពារការសម្រេចចិត្ត"
- អាចមានភាព**បត់បែន** និងអាចកែប្រែបាន។
- យូរៗទៅ អ្នកនោះ**កសាងជំនាញសម្រេចចិត្ត** និងរៀនសូត្រពីកំហុសឆ្គង។
- អាច**ប្រើនៅរដ្ឋណាក៏បាន** រួមទាំងម៉ាសាឈូសេត។
- អាចប្រើវា**ដោយមិនចាំបាច់ជួលមេធាវី និង ដោយមិនចាំបាច់ឡើងតុលាការ**។

# តើអ្វីជាប្រការ "មិន" ក្នុងការសម្រេចចិត្តដោយមានកិច្ចគាំពារ?

- <u>**មិន**</u>មែន**នរណាម្នាក់ផ្សេង** សម្រេចឲ្យ និងសម្រេចជំនួសអ្នកនោះឡើយ។
- <u>**មិន**</u>មែនអ្នកសម្រេចចិត្តនោះ សម្រេចតែ**ម្នាក់ឯង**ដោយគ្មានជំនួយនោះឡើយ។
- <u>**មិន**</u>មែនអ្នកសម្រេចចិត្តនោះ សម្រេចអ្វីមួយបាន គឺទាល់តែអ្នកជួយគាត់យល់ព្រមនោះឡើយ។
- <u>**មិន**</u>មែនសម្រាប់តែអ្នកដែលមានពិការភាពជាក់លាក់ណាមួយនោះឡើយ។



## សំណួរទី ១ សាកធ្វើតេស្តចំណេះដឹង



# ពិត ឬមិនពិត?

បើតាមច្បាប់រដ្ឋម៉ាសាឈូសេត ឪពុក/ម្តាយបង្កើត ទទួលបានសិទ្ធិដោយស្វ័យប្រវត្តិជាអាណាព្យាបាលលើកូនពិការរបស់គាត់ពេលកូននោះឈានចូលវ័យ ១៨ ឆ្នាំ។

# សំណួរទី ១ សាកធ្វើតេស្តចំណេះដឹង



## មិនពិត

ការណ៍ពិត – បើតាមច្បាប់រដ្ឋម៉ាសាឈូសេត ឪពុក/ម្តាយបង្កើត មិនទទួលបានសិទ្ធិដោយស្វ័យប្រវត្តិ ជាអាណាព្យាបាលលើកូនពិការរបស់គាត់នោះឡើយ នៅពេលកូននោះឈានដល់វ័យ ១៨ ឆ្នាំ។

# សំណួរទី ២ សាកល្បងតេស្តចំណេះដឹង

## ពិត ឬមិនពិត?



ឪពុក/ម្ដាយត្រូវដាក់ពាក្យសុំសិទ្ធិអាណាព្យាបាលភាព នៅពេលកូនពិការរបស់គាត់ឈានចូល វ័យ ១៨ ឆ្នាំ ដើម្បីជួយកូននោះក្នុងការសម្រេចចិត្តរឿងអប់រំ។

# សំណួរទី ២ សាកល្បងចំណេះដឹង

## មិនពិត



**ការណ៍ពិត** – ក្នុងច្បាប់គ្មានត្រង់ណាដែលចែងតម្រូវឲ្យឪពុក/ម្ដាយ ដាក់ពាក្យសុំសិទ្ធិអាណាព្យាបាលភាព ពេលកូនពិការរបស់គាត់ ឈានចូលវ័យ ១៨ ឆ្នាំនោះឡើយ។ មានវិធីផ្សេងៗទៀត ដើម្បីជួយកូនៗរបស់ពួកគាត់ ក្នុងការសម្រេចចិត្តផ្ដែកអប់រំ។ ឪពុក/ម្ដាយ និងកូនៗរបស់ពួកគាត់ គួរគិតមើលជម្រើសទាំងអស់នេះ រួមទាំងការសម្រេចចិត្តដែលមានកិច្ចគាំពារផង។

# Massachusetts 2024 IEP Form - English

## DECISION-MAKING OPTIONS FOR STUDENT*

Complete for student who has turned 18. Please indicate the decision-making option that the student or court-appointed legal guardian has selected:

☐ The student will make their own educational decisions.

☐ The student will share decision-making with their parent, caregiver, or other adult.

**Individual with whom the student will share decision-making:** ________________

☐ The student has delegated decision-making to their parent, caregiver, or other adult.

**Individual to whom the student has delegated decision-making:** ________________

☐ A court has appointed a legal guardian for the student who will make educational decisions.

**Name of court-appointed legal guardian:**

# ទម្រង់ Massachusetts 2024 IEP Form - ភាសាខ្មែរ

## ជម្រើសនៃការសម្រេចចិត្តចំពោះសិស្ស*

បំពេញសម្រាប់សិស្សដែលមានអាយុ 18 ឆ្នាំ។ សូមបង្ហាញជម្រើសធ្វើសេចក្តីសម្រេចដែលសិស្ស ឬអាណាព្យាបាលស្របច្បាប់ដែលតែងតាំងដោយតុលាការបានជ្រើសរើស៖

☐ សិស្សនឹងធ្វើការសម្រេចចិត្តសិក្សាដោយខ្លួនឯង។

☐ សិស្សនឹងចែករំលែកការសម្រេចចិត្តជាមួយឪពុកម្តាយ អ្នកថែទាំ ឬមនុស្សពេញវ័យផ្សេងទៀត។

**បុគ្គលដែលសិស្សនឹងចែករំលែកការសម្រេចចិត្ត៖** ____________

☐ សិស្សបានផ្ទេរការសម្រេចចិត្តទៅឪពុកម្តាយ អ្នកថែទាំ ឬមនុស្សពេញវ័យផ្សេងទៀត។

**បុគ្គលដែលសិស្សបានផ្ទេរការសម្រេចចិត្ត៖** ____________

☐ តុលាការបានតែងតាំងអាណាព្យាបាលស្របច្បាប់សម្រាប់សិស្សដែលនឹងធ្វើការសម្រេចចិត្តលើការអប់រំ។

**ឈ្មោះអាណាព្យាបាលស្របច្បាប់ដែលត្រូវបានតែងតាំងដោយតុលាការ៖**

____________

# ជម្រើសដទៃទៀត សម្រាប់គិតគូរក្នុងផ្នែកអប់រំ?



- ការសម្រេចចិត្តដែលមានកិច្ចគាំពារ
  - ទម្រង់ "FERPA" ការយល់ព្រមឲ្យបញ្ចេញព័ត៌មាន
- ការរួមគ្នាសម្រេចចិត្តក្នុងផ្នែកអប់រំ
- ការចាត់ឲ្យគេសម្រេចចិត្តក្នុងផ្នែកអប់រំ

# សេណារីយ៉ូ

**អរុណ**ទើបចូលវ័យ ១៨ ឆ្នាំ។ គាត់មានពិការភាពផ្នែកបញ្ញាស្មារតី។ គាត់នឹងត្រូវទទួលសេវាអប់រំពិសេស តាមរយៈសាលារៀនរបស់គាត់ រហូតដល់គាត់ចូលវ័យ ២២ ឆ្នាំ។ ទោះបីឪពុក/ម្ដាយគាត់ ចង់ឲ្យគាត់មានបទពិសោធន៍ ចេះសម្រេចចិត្តដោយខ្លួនឯងក្ដី ពួកគាត់បារម្ភខ្លាចសាលារៀននោះ នឹងលែងចែករំលែកព័ត៌មាន ឲ្យពួកគាត់បានដឹងទៀត ដោយសារ**អរុណ**ពេលនេះក្លាយជាមនុស្សពេញវ័យទៅហើយ។ ពួកគាត់ត្រូវការព័ត៌មាននោះ ដើម្បីជួយ**អរុណ** ឲ្យយល់ដឹងថាគាត់រៀននៅសាលាបានប៉ុនណា និងថាតើគាត់ត្រូវការសុំសេវាអប់រំបន្ថែមទៀតដែរឬយ៉ាងណា។ **អរុណ**ជឿជាក់លើឪពុកម្ដាយគាត់ និងចង់បានឲ្យពួកគេជួយគាត់។

តើឧបករណ៍ច្បាប់អ្វីខ្លះ ដែល**អរុណ** និងគ្រួសារគាត់គួរយកមកពិចារណា?

# សំណួរទី ៣ សាកធ្វើតេស្តចំណេះដឹង

## ពិត ឬមិនពិត?



ក្រោយពីសិស្សណាម្នាក់ ឈានចូលដល់
វ័យ ១៨ ឆ្នាំ សាលារៀន និងគ្រូ អាចនិយាយ
ជាមួយឪពុក/ម្ដាយរបស់សិស្សនោះបាន
តែក្នុងករណីពួកគាត់ ជាអាណាព្យាបាលរបស់
សិស្សនោះតែប៉ុណ្ណោះ។

# សំណួរទី ៣ សាកធ្វើតេស្តចំណេះដឹង



## មិនពិត

**ការណ៍ពិត** – ក្រោយសិស្សណាម្នាក់ឈានចូលវ័យ ១៨ ឆ្នាំ សាលារៀន និងគ្រូ អាចនិយាយជាមួយឪពុក/ម្តាយគាត់បាន ឲ្យតែមានការអនុញ្ញាតពីសិស្សនោះ។ សិស្សអាចប្រើទម្រង់ “FERPA” ដើម្បីអនុញ្ញាតឲ្យបញ្ចេញពត៌មាន ដែលទម្រង់នេះផ្តល់សិទ្ធិអនុញ្ញាតនោះ។ ទម្រង់នេះអាចមានប្រយោជន៍ ពេលសម្រេចចិត្តដោយមានកិច្ចគាំពារនៅសាលា។



# សំណួរទី ៤ សាកធ្វើតេស្តចំណេះដឹង

## ពិត ឬមិនពិត?

សិស្សពេញវ័យណាម្នាក់ អាចជ្រើសរើសក្នុង
ការរួមគ្នាសម្រេចចិត្តផ្នែកអប់រំ ជាមួយអ្នក
ដែលខ្លួនទុកចិត្ត រួមទាំងឪពុក/ម្ដាយរបស់
សិស្សនោះផង។ នេះមានន័យថា សិស្សនោះ
និងឪពុក/ម្ដាយ អាចសម្រេចចិត្តរួមគ្នា អំពី IEP
របស់សិស្សនោះ និងសេវាអប់រំផង។

# សំណួរទី ៤ សាកធ្វើតេស្តចំណេះដឹង



**ពិត**

ការរួមគ្នាសម្រេចចិត្ត មានន័យថា សិស្សនោះ និងឪពុក/ម្តាយ សម្រេចចិត្តផ្នែកអប់រំជាមួយគ្នា។ បើឪពុក/ម្តាយ និងសិស្សនោះ មិនយល់ស្របគ្នាលើសេចក្តីសម្រេចផ្នែកអប់រំនោះ គឺត្រូវយកតាមជម្រើសរបស់សិស្សនោះ។

# សំណួរទី ៥ សាកធ្វើតេស្តចំណេះដឹង



## ពិត ឬមិនពិត?

បើសិស្សពេញវ័យណាម្នាក់កំពុងរៀនថ្នាក់អប់រំពិសេស ហើយគាត់ចាត់ឲ្យឪពុក/ម្ដាយគាត់សម្រេចចិត្តផ្នែកអប់រំជំនួសគាត់ គឺសិស្សនោះមិនអាចលុបចោលការចាត់ចែងនេះវិញ បាននោះទេ។ ឪពុក/ម្ដាយនោះ ត្រូវសម្រេចចិត្តផ្នែកអប់រំជំនួសសិស្សនោះរហូត ឲ្យតែសិស្សនោះនៅបន្តរៀននៅសាលា។

# សំណួរទី ៥ សាកធ្វើតេស្តចំណេះដឹង

## មិនពិត



ការណ៍ពិត – កាលណាឪពុក/ម្តាយទទួលបាន ការចាត់ឲ្យសម្រេចចិត្តជំនួសសិស្សក្នុងផ្នែក អប់រំនេះ គឺឪពុក/ម្តាយនោះ ឬអ្នកដែលពេញ វ័យនោះ សម្រេចចិត្តផ្នែកអប់រំជំនួសសិស្ស នោះ បានក៏ដោយសារតែសិស្សនោះជ្រើស រើសពួកគាត់ឲ្យសម្រេចចិត្តជំនួសប៉ុណ្ណោះ។ សិស្សនោះអាចលុបចោលការចាត់ចែងនេះ វិញនៅពេលណាក៏បាន និងអាចយកសិទ្ធិ សម្រេចចិត្តផ្នែកអប់រំនេះមកទាំងអស់វិញ។

# ធនធាន

- https://supporteddecisions.org
- https://www.wearemass.org/supported-decision-making
- https://www.dlc-ma.org
- ឯកសារមេរៀន



# មានសំណួរឥឡូវនេះ ឬចាំបន្តិចទៀត?

- មជ្ឈមណ្ឌលសម្រាប់ការធ្វើបទបង្ហាញជាសាធារណៈ:
  - Mona Igram, Megan Rusciano, and Morgan Whitlatch
  - 413-586-6024, SDM@cpr-ma.org

